# ច្បាប់ស្រី

មានផារដុំនៅ

ផ្ទះលេខ ១០ វិថីឧកញ៉ាផ្លុង

ភ្នំពេញ

គ. ស. ១៩៥៧

CA52

# ច្បាប់ស្រី និង ច្បាប់ប្រុស

( ចម្លងពីច្បាប់ស្លឹករឹត )

ការផ្សាយរបស់

មានផាវដុំនៅ

បណ្ណាគារ តិច · ហុង

ផ្ទះលេខ ១០ វិថីឧកញ៉ាផុន

ភ្នំពេញ

គ. ស. ១៩៥៧

# ច្បាប់ស្រី

## បទកុជន្តលីលា

នេះបទប្រាកដឯងជា កុជន្គលីលា ចងជា ច្បាប់ស្រី ។ កាលនាងឥរទ្ទេវី ចរចាកតាមប្តី ពីបណាកយក្សា ។ នាងវិមលាជាព្រះមាតា ហើយទូលថា ហៃកូនពិសី ។ នាងនឹងត្រាច់ ត្រង់តាមប្តី ចេញចាកអំពី ពិភពនាគនេះ ។ ទៅស្ថានមនុស្សលោកនាយអេះ ចូរនាងចាំចេះ បំរើស្វាមី ។ ធ្វើវត្តប្រតិបត្តិប្រក្រតី កុំឲ្យស្វាមី តាក់អន់ចិត្តា ។ នាងអើយតម្កើងក្រឡា ជាម្ចាស់សិរសា កូនកុំមាក់ងាយ ។ ហៃកូនស្រី ស្ងួនជាសម្លាយ ក្រណាស់នាងអើយ តាម

ដោយច្បាប់ស្រី ៗ ក្រមួយមិនបានសំដី ពាក្យ

ទន់តិចនៃ ឲ្យញាតិចូលចិត្ត ៗ ក្រមួយមិនបេះរេះ

គិត ឃើញញាតិឆ្ងាយជិត ហៅឡើងពីស្វា ៗ

ទោះមានមិនមានក្តីណា ពាក្យផ្អែមបរោ ទើប

គេស្រឡាញ់ ៗ កុំជួបចិត្តស្ទកំណាញ់ មិនមាន

អស់អញ ទឹងញាតិសន្តាន ៗ កើតយស

របស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះ

កូនស្រី ៗ ទោះទឹងនិយាយស្រដី ការក្តើជា

ស្រី កុំស្តីលេះលោះ ៗ ជាលេងដូចក្មេងញ៉េះ

ញ៉េះ ឃើញប្រុសកំឡោះ សរសៀរចូលជិត ៗ

សើចព្រៀងចញ្ចៀងមិនគិត ប្រុសព្រើលបាន

បិត្តា បានដោយសារ ។ ហៅស្រីអប្រិយឥតការ ឥតមានឥរិយា មារយាទក្នុងខ្លួន ។ សើរើពុំធ្វើ ទឹងទ្លួន ស្រដីមិនមួន មិនមានគៀនគន់ ។ ឃើញ គេបៀនបៃគេយកគន់ សើចស្លូវបំអន់ បំអកឲ្យ ប្រុស ។ ហៅស្រីអប្រិយ៍ទុរយស មិនគិត ខ្លួនខុស មារយាទក្រិត្យក្រម ។ ធ្វើការអង្គុយ ប្រឡំ ទឹងសមពុំសម ផ្កាឯងជាស្រី ។ មិន គោតមិនខ្លាចចិត្តប្ដី ឲ្យប្រុសដទៃ មាក់ឆាយថ្ដី ណា ។ ហៅស្រីឥតលក្ខណា ឥតមានឥរិយា មារយាទពុំសម ។ ធ្វើការផងណាប្រើខំ តោះ ត្បាញចាក់ដំ នាងខំឲ្យហើយ ។ កុំទុកទៅមុខ

ទៀតឡើយ ថាចាំបង្ហើយ កម្រណាស់ណាស់
នោះធ្វើហូលគោមគាតផ្កា ដាក់ត្បាញហើយណា
បានស្រេចសមធ្វើ ៗ ធ្វើឲ្យកើតកេរ្តិ៍ប្រសើរ
ហើយកុំឲ្យដើរ លេងផ្ទះគេណា ៗ នុស្សនខ្ទឹម
ខ្លួនរក្សា នានីចាំធ្វើការពាន់ខ្លួនក្រមុំ ៗ មាន
ប្តីបានអ្វីជាចំ រវល់កូនយំ កម្របេះធ្មៀត ៗ
ព្រួយចិត្តគំនិតចង្អៀត មួយហើយមួយទៀត
យំទារតែស៊ី ៗ រឺព្រួយចាំងមួយចាំងពីរ រក
បានឲ្យស៊ី ទើបបានបាត់មាត់ ៗ នោះកាន់ការធ្វើ
ឲ្យស្អាត ហូលគោមគាតកាត់ អន្ទង់ត្បាញទៅ ៗ
កុំខុកកន្ទង់ស្កកស្ញទៅ ក្រែងដល់យូរទៅ ខាត

ខូចអសារ ។ ហៃកូនស្រីសួនមាតា ចូរចាំរក្សា
កុំភ្លេចស្មារតី ។ ចូររករៀនយកច្បាប់ស្រី ឲ្យ
កោតខ្លាចប្ដី គម្ដែងក្រឡា ។ ធ្វើវត្តប្រតិបត្តិ
សោតណា ឲ្យនាងរក្សា ភ្នក់ភ្លើងទាំងបី ។
ឲ្យកាត់ឲ្យគង់ប្រក្រតី សព្វថ្ងៃកុំបី ភ្លេចផ្ដុំឲ្យ
ឆេះ ។ ក្រែងកលដូចដាលព្រាយប្រុះ កើតក្ដៅ
រលេះ រលាកអស់អង្គ ។ ភ្លើងក្រៅកុំនាំទៅក្នុង
ឲ្យឆេះបំផ្លុន រឹងផ្ដុំបង្កាត់ ។ ភ្លើងក្នុងមិនប្រុងប្រយ័ត្ន
នាំមកបង្កាត់ ឲ្យឆេះឯក្រៅ ។ គុជអាលបណ្ដាល
ឲ្យក្ដៅ ដាលដល់កូនចៅអសោចអប្រិយ៍ ។
ឲ្យនាងខំប្រុងស្មារតី មើលភ្លើងទាំងបី រក្សាឲ្យ

គង់ ។ ក្មេងនោះឲ្យគុណពុំលង់ ទីងបានឧត្តុង្គ
ឧត្ដមគន្ធ ។ កើតយសរបស់ទ្រព្យផង បរិបូណ៌
ឥតហ្មង ប្រសើរក្ដាត់ណា ។ ក្មេងមួយនោះឲ្យ
រក្សា គឺគុណមាតា បិតាស្ងួនគ្រង ។ ឲ្យនាងធ្វើ
ដោយគន្ធ ប្រណិប័តន៍កុំឆ្គង ទីងម្ដាយឪពុក ។
ឲ្យទំថែទាំញ៉កញ៉ុក បំណីបំណុក បំណង់អាត្មា ។
កុំឃ្លានខុកស៊ីឡើយណា ទាញញ៉ូឈ្មួយពិសា ជូនៈ
ជាប្រក្រតី ។ ពាក្យពេចន៍ការកិច្ចអ្វី ៗ អត់ធុនកុំបី
ឲ្យអាក់ចិន្ដា ។ ក្មេងមួយគម្ដង់ក្រឡា គឺប្ដីអាត្មា
បិតបេះរូមរក្ស ។ ឲ្យនាងប្រណិប័តន៍ដៀនជាក់
កុំធ្វើឲ្យអាក់ ឲ្យអន់ចិត្តប្ដី ។ អន់ធុនខ្ជាបខ្លួនជាស្រី

កុំឲ្យស្រដី ខុសគេជាស្មើ ៗ ពោះកើតហេតុគេ

សារពើ ពាក្យពុំប្រសើរ ជញ្ជឹងបាំស្អាថ ៗ

ពោះបីស្រដីពុំគាប់ ពុំគួរឲ្យប្រាប់ បានដឹងផល់

ម្តាយ ៗ កើតខឹងរៃរង់ខ្ញូរខ្ញាយ ព្ធពាក្យពីម្តាយ

ខ្សឹបខ្សៀវប្រាប់ក្តី ៗ មិនគ្រាន្តថៃកបានពីរបី កើត

ជាសំដី សួរបុះសួរឡើង ៗ ពុំស្ងាត់ស្ងៀមមាត់

បរើង ជជែកនាំឡើង បរើងមិនបាត់ ៗ គតាំង

ពាក្យខ្ញាំងមិនស្ងាត់ មិនស្ងៀមឲ្យបាត់ ឲ្យបានទី

សុខ ៗ ជជែកស្ទើរបែកតាំងស្រុក មិនមានហៅ

សុខ យូរលង់ឡើយនៃ ៗ នេះហៅក្អកក្អើងតាំងបី

ម្តាយផ្តាំកូនស្រី ឲ្យចាំថែរក្សា ៗ នាងអើយ

តម្លៃក្រឡា ខុសគ្គងម្តមម្តា ម្តាយផ្តាំកូន

ស្រី ៗ ឲ្យគត់សង្កត់ហឫទ័យ កូនកុំស្រដី
ដើមប្ដីកំបាំង កំដេរកុំចេញជាខ្លាំង ខ្សត់ខ្សោយ
ទៅខ្លាំង នានកុំមើលងាយ ៗ ល្ងង់ក្រោយប្រើឲ្យ
និយាយ ណែនាំលេងលាយ ឲ្យស្រួលរាបា ៗ
ពេះបើស្រដីម្ដងម្ដា ទេទឹងដេរថា ទោះពាក្យ
ទម្ងន់ ៗ ក្រោធក្រេវក្ដុរក្ដៅមិនសន់ មិនអាក់
ស្រាកស្រន្ត ដោយចិត្តខ្នាន់ខ្នាញ់ ៗ វង្វេងនាំ
ទន្ទេញ ដេរថាជន្ទេញ ផ្សិតពាសទទឹងចិត្ត ៗ
ឲ្យកូនស្រីស្ងួនខំអត់ ឲ្យបានរលត់ រលាយកុំ-
ហឹង ៗ កុំឲ្យតាន់ខ្លួនប្រែប្រឹង តតបតៅទឹង អ្នក
ជាស្វាមី ៗ ទេទឹងក្រញឹងសំដី មិនគិតខ្លួនស្រី

ស្រដីទ្រគោះ ៗ ប្រកែកស្ដីពាក្យគំរោះ គំរាម
បញ្ឆោះ បញ្ឆោរឲ្យខឹង ៗ រឹងរុសមើលមុខសំឡឹង
សំឡក់ទៅរឹង បចើងនាំឈ្លោះ ៗ រឹងធ្ងន់ធ្ងើយពាក
បញ្ឆោះ បំបែកជាឈ្លោះ បំបែមិនទៀង ដេរ
ជាថ្កូធ្មាបំព្រៀង ដៀលត្មះបញ្ញៀង បញ្ជី
ចិត្តបី ៗ ហោកហោះទ្រគោះអ៊ឺៗ ចាក់ចោលទៅដី
បែកបាក់ពុំគិត ៗ មិនស្រួលទទួលបាត់មាត់
ម្នះម្នេញក្នុងចិត្ត ៗ ឲ្យបានប្ដីចាញ់ ៗ ទើបបាន
សុខចិត្តជាវិញ ហៅស្រីម្នះមិញ អាប់កេរ្តិ៍យស
ធ្លាយ ៗ ហៃកូនស្រីស្ងួនមាសម្ដាយ ខុសណាស់
នាងក្សាយ កុំធ្វើដូចគេ ៗ គោរពបើប្ដីទាន់ដេរ

នាងចូលទៅឯ ដំណេកគិតសិន បើញមកនាង

យកពាក្យទន់ ស្រដីផ្អែមន់ ស្រាយទោសនោះ

ទៅ ៗ ទោះបីប្ដីប្រដៅ ចូរនាងចាំនៅ ទុក

ក្នុងអាត្មា ៗ ពាក្យពេចន៍ពុំក្បួបឡើយណា ក្រែង

ជូនមេបា ដូចគ្មានថ្នាំស្រាប់ ៗ ព្រោះ

ឯងមិនក្រែងមិនស្ដាប់ ពាក្យគេបង្គាប់ បន្ទើក

តែឈ្មោះ ៗ ឥតសុខអាក្រក់តែឈ្មោះ ត្រូវតែ

ប្រឈ្មោះ មិនបេះហៅហ្លៃ ៗ នេះពុំកប់ជាស្រីទេ

ជាអ្នកប៉ៅក្លៃ ចិត្តចោរដងខន ៗ ឲ្យមាត់

បង្គ្រឹបប្ដីផង ឲ្យគេស្ដាប់បាន ថាឯងគ្រាន់

ថើ ៗ គឺមោះនាងនោះមិនប្រើ មិនថើកឲ្យ
ដើរ ថញ្ញីឲ្យទេ ៗ តោះបីប្ដីប្រើមាសមេ កុំ
កូនដំកែ ដំអក់មិនទៅ ៗ ធ្វាយដិតកុំនិត្យរង់នៅ
ក្រោកក្រេសដើរទៅ ៗ កុំឲ្យប្ដីដេរ ៗ កុំទៅយូរ
នៅផ្ទះគេ វិលចំនេរ រវៀសមកណា ៗ ឱកូន
ខ្ញឹមខ្ញួនមាតា ជាស្រីនេះណា កម្រណាស់នាង ៗ
មិនថាផ្សិតល្អរូបពង មិនរើសផ្សិតជាង បេះការ
ទាំងគ្រប់ ៗ មិនបានស្គាល់ទីគោរព ស្គាល់តែឧបៈ
ទ្រព ទាំងដប់ប្រការ ៗ ហៅតែនឹងល្អរូបា តិច
ហើយបេះការ គួរគោតរដោយយ៉ាង ៗ មួយល្អ

រូបសស្រឡាង ឥតគេផ្ទឹមទាន ច្បាប់ផងមិន
បេះ ៗ ល្អពិតគំនិតមិនផេះ ទោះខ្មៅក្រនេះ
ការសោតសមគួរ ៗ គឺមោះនាងនោះមិនដួ បេះ
ធំសមគួរ ស្គាល់អស់ឥរិយា ៗ នេះឯងពីព្រេង
លោកថា ហៅល្អរូបា កបកល្យាណី ៗ
ហៃកូនស្រីស្ងួនពិសី ម្ដាយប្រាប់អំពី ឧបទ្រព-
ចង្រៃ ៗ កាន់ក្បាលប្ដីហើយរកថៃ មិនបាន
លើកដៃ បិតទូលសំពះ ៗ លោកគុកស្ទុក
ទំផ្ទះ រង្គំរង្គះ ទិញបង់អស់ទ្រព្យ ៗ កន្ទង់ដើនប្ដី
ពុំគាប់ ព្រោះចិត្តចង់ឆាប់ រំលងដើនប្ដី ៗ

ស្មើសត្វលលកខ្មោចខ្មី ហើរប្រាសអប្រិយ៍ វគឹត ព្យាធិពេគា ៗ ចង្រៃមួយនៃពល់គ្នា ចេញចូល មាត់ទ្វារ ពុំបានបិទបាំង ៗ ភ្លេសប្រាណខុស ខានមិនពាំង មិនរុញចំបាំង មើលយល់សាយ សុស ៗ ទុកស្មើគេអុជចន្ទុះ ឲ្យពោរចូលចុះ យក ទ្រព្យទាំងឡាយ ៗ ស្រីមួយសើចលេងក្អាកក្អាយ ភ្លេចចម្ងាយរំលងផ្ទះបី ៗ ស្មើសត្វចចាតបក្សី ចូលភូមិផងក្តី ចង្រៃក្តាត់ណា ៗ ស្រីមួយដាក់ជេក កាយា ប្រះប្រែអាត្មា ឲ្យខ្លួនទៅថ្ពី ៗ ទុកស្មើពស់ ក្រាយអប្រិយ៍ ឡើងផ្ទះឥតបី ឥតបើគណនា ៗ ចង្រៃកាចក្រៃពុំជា រឹងព្រាត់ប្រាសគ្នា ពុំបានវែង ឆ្ងាយ ៗ ស្រីមួយសក់វែងអន្ទាយ រំសុះរំសាយ

សក់សោតរោក ៗ នៅមាត់អណ្តូងមាត់ទ្វារ បី
ដូចមដ្ឋក ធ្លាណាក់ក្រុចគ ៗ ចង្រៃឥតបីបើរក
រកសំគក មិនបុកសក់ងាយ ៗ ស្រីមួយដើរ
ទៅតាត់ផាយ ព្រលាន់ស្មើរផ្កាយ ប្រថពីសន្ធឹក ៗ
សំពត់ផាប់ផាប់មិនគិត ដើរព្រឹតគឹក ស្មើស្មូររន្ទះ
ញាំញើដំណើរលលះ ផាក់ជើងលើផ្ទះគគ្រាំ
គគ្រេង ៗ គគ្រើគទាំងផ្ទះបីល្វែង ដូចគលគេសែង
របស់ចេញទៅ ៗ ស្រីមួយឃើញទ្រព្យនៅផ្លូវ គន្ទង
ហួសទៅ មិនចាប់ចេញទុក ៗ តុំថេរបំណោរទៅ
មុខ តុំបេះដាក់ទុក រាយរាល់តែល្វែង ៗ ទ្រព្យនោះ
រលោះចេញឯង ចង្រៃតាស់ខែង ធ្វើឲ្យអន្តរាយ ៗ

ពោះធំចំណីខ្ញូវផាយ លបលួចកកាយ តមពុំ
សណ្ដាប់ ។ កូនអើយនេះហើយបូរស្ដាប់ ហៅក្ដី
ឧបទ្រូត ទាំងដប់ប្រការ ។ ឲ្យជៀសអស់ទាំង
នេះណា ឲ្យរៀនលក្ខណា ទាំងប្រាំពីរផង ។
គឺព្រះមានបុណ្យគន្ធង ទេសនាចែងចង ជាបទ
គាថា ។ មួយមាតុមួយមិត្តភរិយា ភាតុភរិយា
ជា- ទាសភរិយាផង ។ ទាំងបួនប្រសើរឥតក្លួង
គួរឲ្យចាំបង ទុកក្នុងអង្គា ។ រីឯហៅមាតុភរិយា
ប្រពន្ធនោះជា ពោធទុកស្នើមាយ ។ ចរិតបី
ប្រការក្នុងកាយ មួយចង់ខ្វល់ខ្វាយ ប្រយោជន៍
ឲ្យប្ដី ។ បានប្ដីនរុងរឿងឮល្បី មិនឲ្យអាប់ប្ដី

ឲ្យបានសក្តិយស ៗ មួយបើប្តីស្លៀកពាក់ចាស់

យកថ្មីឲ្យផ្លាស់ ចាស់ស្លៀកខ្លួនឯង ៗ បេះរៀប

រណ្តាប់តាក់តែង ចំណីផងស្ងួន រកមកឲ្យប្តី ៗ

មួយបើប្តីឈឺថ្កាត់អ្វី ព្រួយប្រឹងមើលប្តី រកថ្នាំសង្កូវ ៗ

រកពេទ្យមេមត់ទូវគ្រូ គ្រោះយាមគន់គូរ មើល

ប្តីឲ្យជា ៗ រីឯហៅគាតុករិយា ប្រសើរសោភា

ប្រពន្ធស្មើបង ៗ នោះមានបរិតពីរហោង ដូចប្អូន

និងបង ចិត្តមូលមួយប្រាណ ៗ មួយធ្វើឲ្យប្តី

ក្សេមក្សាន្ត របស់ប្តីបាន បេះដុតគេក្សា ៗ មួយ

ទោរព្ទពាក្យអ្នកណា គេតិះដៀលថា ស្រដីពីប្តី ៗ

ពុំត្រូវអាស្រ័យអប្រិយ៍ ពេះការកើតថ្មី ថែរបានជា សុខ ៗ ទោះបីបើប្ដីមានទុក្ខ គិតឲ្យបានសុខ យកខ្លួនជានា ៗ មួយ សោតឯមិត្តភរិយា មានចរិតជា បីប្រការមិញ ៗ បីដូចកលមិត្តសំឡាញ់ មានចិត្ត អស់អញ មិនឲ្យមានហ្មង ៗ បីដូចកលប្អូននឹងបង ប្រាសប្អូរលង់ហោង ទើបមកជួបគ្នា ៗ មានចិត្ត ប្រតិព័ទ្ធមហិមា ដ្បិតបានជួបគ្នា មិនឲ្យមានហ្មង ៗ មួយមានមារយាទគន្ធង ទោះឃើញប្រុសផង មិន ស្មៀនចិត្តទៅ ៗ រីទាសភរិយានោះក្ដី ក្នុងមាត្រា ត្រូវ ប្រពន្ធខ្ញុំប្ដី ៗ ចរិតប្រាំប្រការនេះ មួយចិត្តខ្លាចប្ដី ក្រែងប្ដីវាយជេរ ៗ ប្រុងចិត្តការគិតខ្លាសគេ មិន

ឲ្យប្ដីដេរ អង្គាសខ្លួនបាន ។ ពោះបីទឹនក្រៃប៉ុន្មាន
មិនបេះហៅហ៊ាន ឆ្លើយឈ្លោះតមាត់ ។ មួយ
ពោះប្ដីនោះគាបក្ដាត់ ទំនឹងសល់វាយវាត់ ដេរ
ពោះផុតទង ។ មិនហ៊ានឆ្លើយឈ្លោះរំលង គតប
ទៅផង ក្រែនព្រគ្រឿងដង្វាយ ។ មួយបេះប្រដាប់
រៀបបាយ ប្ដីដើរជិតឆ្ងាយ មិនហ៊ានបរិភោគ ។
សត់ទ្រាំទំរាំប្ដីមក ជួបជុំទើបយក បរិភោគផងគ្នា ។
នេះឯងហៅទាសភរិយា សម្ដេចភគវា ទេសនា
ប្រោសប្រាប់ ។ បើអស់ស្រីណាបានស្លាប់
យកទុកជាច្បាប់ ក្នុងប្រាណសព្វថ្ងៃ ។
លុះអស់អាយុក្សិណក្ស័យ បានទៅកើតឮ

តុសិតសួគ៌ាល័យ ។ ទីឋានក្រៀមក្រាន្តពណ្ណ-រាយ សេពសុខសប្បាយ និរទុក្ខភ័យា ។ រីឯប្រពន្ធពុំជា ពេជ្ឈឃាតករិយា ចរិតមានប្អូន ។ កុំឲ្យយកទុក្ខក្នុងខ្លួន ឲ្យជៀសចេញផុន កើតកម្មវេរា ។ មួយចិត្តគំនិតបងជា ក្លាស ក្តើយចំពារ ចំពានឲ្យប្ដី ។ ប្រចូស្ដារីរូសខ្វីវី មិនបេះបាញ់ប្ដី ថាឯងគ្រាន់បើ ។ ក្តើយក្ដូនសួរ សនបណ្ដើរ ចង់ឈ្មោះឲ្យស្មើ ឲ្យលើសប្ដីវិញ ។ មួយមិនចង់ធ្វើបំពេញ បង្អាប់ប្ដីវិញ ឲ្យថ្កើនខ្លួន

ឯង ៗ អានបេះដៀលតិះពុំក្រែង ឲ្យប្តីស្លាប់ឯង

ដោយចិត្តអន្ធពាល ៗ មួយមានចិត្តនោះស្រើប

ស្រាល ចង់គ្រេកគ្រអាល ហោរចេញក្បត់ប្តី ៗ មួយ

ចិត្តទ្រើសទ្រុស្តអប្រិយ ចង់សម្លាប់ប្តី ស្រឡាញ់

ប្រុសទៀត ៗ គិតកាប់សម្លាប់ចង្សៀត ខឹង

យកប្រុសទៀត ធ្វើប្តីមរណា ៗ រីឯសត្រូវកិរិយា

ចរិតពុំជា ប្រាំពីរប្រការ ៗ មួយមិនខ្លាចប្តីអាត្មា

បង្គាប់គ្រន់ណា ពុំធ្វើតាមចិត្ត ៗ មួយរឹង

ទ្រមឹងស្ងៀមស្ងាត់ ប្តីសួរចំមាត់ ពុំស្រដីផង ៗ

មួយប្តីស្រដីតទ្ទង ប្រដៅច្បាប់ផង ពុំចូល

ចិត្តស្ដាប់ ។ មួយមិនចង់ឲ្យប្ដីគាប់ មិនចង់
ប្រដៅបី ឲ្យប្ដីចំរើន ។ មួយពោះទឹងស្រដី
ឡើង ពាក្យធំបើន ចាបេសទឹងប្ដី ។ មួយទោះ
ប្ដីលោះខ្ញុំស្រី រាប់រើប្ដី មិនឲ្យគាក់អន់ ។ ឃើញ
គាប់រឹងស្អប់ក្នាញ់គ្នាន់ ក្នុងចិត្តប្រច័ណ្ឌ ដេរដៅ
នាយគាយ ។ មួយដៀតប្ដីមានសហាយ ហួរហែក
សុះសាយ ឲ្យប្ដីគាស្រវ ។ រំពោរគរិយា
នោះគួរ ចរិតពុំត្រូវ មានបីប្រការ ។ មួយចង់ចាយ
ទ្រព្យប្ដីណា ឲ្យខូចគសារ មិនគង់ជាល្អ ។ មួយ
ប្ដីឃ្លាតខ្ទីខំរក របស់បានមក មិនថែទាំទុក ។
លួចឲ្យទៅម្ដាយឪពុក ប្ដីសួររកមុខ មិនប្រាប់

ទៀយណា ៗ មួយវិញ្ញលមិនចង់ធ្វើការ កុហកមុសា
ថាឯងវល់ ៗ ដេកលេងចំរៃងអស់កល លុះប្ដី
គេយល់ ពុតធ្វើជាឈឺ ៗ ទទូរដេកថ្ងូរហ៊ីៗ ប្ដី
ហៅមិនព្ញ ពុតចង់តែស្លាប់ ៗ នេះហៅប្រពន្ធពុំ
គាប់ ស្រីណាកាន់ខ្ជាប់ ពុំដែលរសាយ ៗ លុះ
អស់អាយុក្ស័យក្ខាយ ធ្លាក់ទៅអបាយ ទាំងបួន
ដំពូក ៗ តែងនឹងរងទុក្ខរងសោក រដោះរួចមក
កើតជាមនុស្សទ្វើយ ៗ ហេតុអកុសលនេះហើយ
ជៀតខ្លួនឥតត្រើយ ធ្វើខុសគន្លង ៗ ខុសវត្ត
ប្រតិបត្តិផ្ដាំផ្ដួន មិនរៀនមិនរង ខុសទំនងច្បាប់
ស្រី ៗ មាក់ងាយនោះមានប្រាំបី មានគុន

ផាលី ព្រះធម៌លោកថា ។ មាក់ឆាយមួយ
នោះឯងណា ផ្សិតប្តីពិការ មិនបានមួនមាំ ។
ខឹងស្អប់ធុញថប់មិនទ្រាំ មិនមានរកថ្នាំ គ្រូគ្រោះ
មេមត់ ។ មើលប្តីឲ្យដាំឆាប់ឆុត ខឹងវិញមិនអត់
បន់ប្តីឲ្យស្លាប់ ។ មាក់ឆាយមួយប្តីខ្សត់ទ្រព្យ
គ្មានកេរ្តិ៍គោះគាប់ ស្មើរទឹងគ្នា ។ ដៀលត្មះ
ថាព្រាសដោយសារ ព្រោះខ្ជិលធ្វើការ ទើប
គ្មានរបស់ ។ មាក់ឆាយផ្សិតប្តីសព្វយស ឯង
ត្រកូលខ្ពស់ ពូជពង្សពុំស្មើរ ។ ធ្វើងខ្លួនឲ្យប្តីបំរើ
ឈ្មោះឡើងហើយដើរ ដៀលត្មះពូជពង្ស ។
មាក់ឆាយមួយផ្សិតប្តីល្ងង់ខ្លៅខ្លួនទ្រមង់ ទ្រមក់
ឃើតឃ្យូរ ។ ដៀលត្មះពុំឲះគាស្ងួរ សំដីខ្លោះខ្វូរ

មិនក្រែងចុំនសក់ ៗ មាក់ង៉ាយមួយប្ដីអាក្រក់
សាច់ខ្មៅចិចក់ មុខមុតស៊ីសុស ៗ កន្ទ្រួលភន
លេក្រខុះ សក់ស្កាញ់សូវស្កុះ ពោះធំប៉ុនពាង ៗ
ខ្លួនឯងនឹងចែញ្ចែងរូបពន ខ្លួនស្អុយជាង ជាប្ដីមិនសមៗ
មាក់ង៉ាយមួយប្ដីមិនខំ ធ្វើការលោលៅ ឡេវឡេវ
ដើរលេង ៗ ធ្លៀតធ្លើយពោះពាក្យគេក្រេង ឈ្មោះ
ដេរមិនឈ្នេង គិតខុសមាត្រា ៗ មាក់ង៉ាយមួយ
ប្ដីផឹកស្រាស្រវឹងចោលការដើរលេងតែលតោល ៗ
ពាក្យគ្រូនាំប្រៀនឡេា ៗ ឲ្យតែព្រះធោ ផ្អើល
ក្បាក់គួនទៅ ៗ ញាត់ប្ដីហើយខឹងក្ដៅ ប្រទេចជេរ
ទៅ តាមដោយចិត្តក្នាញ់ ៗ មាក់ង៉ាយមួយទៀត
នោះមិញ ដៀតប្ដីស្រឡាញ់ លលូកប្រឡែង ៗ

មូលក្ដិចហាក់ចុះជាល្បែង មិនមានកោតក្រែង
បានចិត្តជេរវិញ ៗ ដ្បិតតែយល់គេស្រឡាញ់
សំដីផងមិញ គំរោះគំរើយ ៗ ធ្វើក្នាញ់ថែវចេញ
ព្រានើយ ទេវទឹកទ្ដើយ កិច្ចក្ច់បរិយា ៗ ពុំបាន
គ្រៀមក្សាន្ដទីនគ្នា មាក់ងាយនេះជា គំរប់ប្រាំបី ៗ
កូនអើយនេះហើយច្បាប់ស្រី ឲ្យកូនពិសី រគរៀន
រក្សា ៗ យកទុកក្នុងអង្គសាគ្នា ប្រសើរក្ដាត់ណា
កើតសុខសួស្ដី ៗ ប្រសើរតាំងនាលោកីយ
ទោះបរលោកក្ដី សឹងលុះប្រាថ្នា ៗ ទោះចិត្ត
តន់គិតសច្ចា ជាពុទ្ធមាតា សឹងបានបរិបូណ៌ ៗ
ដូចចិត្តឆាប់ឆុតពុំយូរ គបកើតសម្បូណ៌ សម្បត្តិ
ទ្រព្យផង ៗ កើតយសខ្ពង់ខ្ពស់កន្ទង យីនយូរ

ឥតហ្មង ដូចក្តីប្រាថ្នា ៗ ច្បាប់នេះឧត្តមថ្លៃថ្លា
ទោះស្រីឯណា ឮហើយមានភ័ព្វ ៗ ជាល្អកម្រ
បានស្តាប់ ស្តាប់ចូរចិត្តចាប់ ចូរចាំគ្រប់គ្នា ៗ បាន
ដល់មគ្គផលសួគ៌ា ប្រសើរសោភា ចូរចាំកុំភ្លេច ៗ
ចរចាគស់សាចិពាក្យពេចន៍ ពាក្យឥតកាព្យកិច្ច
បរិបូណ៌ប្រពៃ ៗ ស្រជ្រៃប្រវឹងនាមនៃ ខ្ញុំឈ្មោះ
ម៉ឺន „ម៉ៃ„ មែនមានសទ្ធា ៗ មានចិត្តគួបគិតកាព្យ
កបកើតជ្រះថ្លា ត្រេកត្រេនកុសល ៗ សទ្ធាប្រាថ្នា
មគ្គផល ផុលផុះយោបល់ លេបឡើងទុកទៅ
ទោះបីសេចក្តីខុសត្រូវ សូមទានជម្រូវ ជម្រន់ឲ្យ
ផង ៗ កុំត្នះតិះដៀលឡើយហោង សូមសាន

ផលផលី ទុកសាសនា ។ សម្រាប់ជាច្បាប់
មាត្រា សូរេចប្រការ បរិបូណ៌ចែនចប់ ។

=ចប់=

## ពាក្យពន្យល់

កុជន្គលីលា= ឆាគដើរ

គម្តែនក្រឡា= ជាធំលើផែនដី

អស់អញ= អើពើ. រាប់រក. រវល់

ការកេរ្ដិ៍= រក្សាកេរ្ដិ៍. ការពារកេរ្ដិ៍

ទុរយស= បោកទាប. អាក្រក់

អសារ= គ្មានប្រយោជន៍

អសោចិអប្រិយ= ស្អុយអាក្រក់

ពុំលន់= ពុំយូរ

ជនេន្ញ= ល្អូកល, ជិន្ទ

ចំព្រៀន= ហោកទាប

ចៅខ្សែ= ឥតទៀងទាត់កន្លែង

ជគចន៍= ពាក្យជេរទៅលើមនុស្សស្រី

ផ្ទឹមខាន៍= ផ្ទឹមក្បែរ, ផ្ទឹមជាមួយ

គល្យាណី= ស្រីជាមិត្តគួរស្រឡាញ់

បិទទូល= លើកដៃសំពះឡើងលើ (បន្ទូល)

បទគាថា= សេចក្តីជាវគ្គប្ញា

តុសិត= ឈ្មោះស្ថានសួគ៌ជាន់ទី ២

ពណ្ណរាយ= ធ្វើឲ្យមានពណ៌ព្រោងព្រាយ

និរទុក្ខភយា= ឆ្ងាយពីទុក្ខភ័យ

អន្ធពាល= ពាលកំឡៅ, គគំគងងល់

អបាយ= ស្ថាននរក

មូលនិធិខ្មែរសម្រាប់ការសិក្សា ករុណាខ្មែរ

ឃីម បូរ៉េន

មេសា ឆ្នាំ ២០១៥

# បណ្ឌិតប៉ែន សេដ្ឋារិន

ដើម្បីបម្រើប្រយោជន៍សាធារណៈ ដោយមិនគិតយកកម្រៃ

ខ្មៅ យុនសំរ៉ង

រោងពុម្ពសិង្ហ
៤៦៥ មហាវិថីព្រះបាទមុនីវង្ស

តម្លៃ ៣រ០០